**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៣៧ សហវ.ដបក

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១១

# ប្រកាស

## ស្តីពីការបង្កើតក្រុមការងារគ្រប់គ្រង និងអនុវត្តអនុកម្មវិធីទី៤ របស់ផែនការអនុវត្តរយៈពេល ៣ឆ្នាំ (២០១១-២០១៣) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស /រកម /០៥០៨ /០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការបង្កើត និងដាក់ឲ្យអនុវត្តចំណាយប្រតិបត្តិការអាទិភាពក្នុងក្របខណ្ឌសហប្រតិបត្តិការអភិវឌ្ឍ

- បានឃើញសេចក្តីសម្រេចលេខ ៥៦ សសរ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៧ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងឯកសារផែនការអនុវត្តរយៈពេល ៣ឆ្នាំ (២០១១-២០១៣) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## សម្រេច

**ប្រការ ១** : ត្រូវបានបង្កើតក្រុមការងារសម្រាប់គ្រប់គ្រង និងអនុវត្តអនុកម្មវិធីទី៤ របស់ផែនការអនុវត្តរយៈពេល ៣ឆ្នាំ (២០១១-២០១៣) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១០-២០១៩) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលហៅកាត់ថា «ក.គ.អ.អ»។

**ប្រការ ២** : ក.គ.អ.អ មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- | ឯកឧត្តម ជូ គឹមឡេង | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រធាន |
| ២- | លោក លីវ ប៊ុនហៃ | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ជាអនុប្រធានទទួលបន្ទុកសម្របសម្រួលការងារអភិវឌ្ឍន៍សមត្ថភាព រដ្ឋបាល និងហិរញ្ញវត្ថុ |
| ៣- | លោក ប៊ូ វង្សសុខា | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ជាអនុប្រធានទទួលបន្ទុកសម្របសម្រួលការងារទីប្រឹក្សាជាតិ និងអន្តរជាតិ |
| ៤- | លោក វង្ស វ៉ូដាវុឌ | អនុប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ ជាសមាជិកទទួលបន្ទុកការងារអភិវឌ្ឍន៍សមត្ថភាព |
| ៥- | លោក ឈាន ហៀង | ប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានរតនាគារជាតិ ជាសមាជិកទទួលបន្ទុកការងារអភិវឌ្ឍន៍សមត្ថភាព |
| ៦- | លោក ចាន់ ធី | ប្រធានការិយាល័យ ជាសមាជិកទទួលបន្ទុកការងារអភិវឌ្ឍន៍សមត្ថភាព |
| ៧- | កញ្ញា វណ្ណ ច័ន្ទប្រាថ្នា | មន្រ្តីនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ជាសមាជិកទទួលបន្ទុកការងាររដ្ឋបាល |
| ៨- | លោក សឿង វុត្ថារ៉ា | មន្រ្តីនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ជាសមាជិកទទួលបន្ទុកការងាររដ្ឋបាល |
| ៩- | លោក គង់ វឌ្ឍនៈ | ប្រធានការិយាល័យនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ជាសមាជិកទទួលបន្ទុកការងារហិរញ្ញវត្ថុ |

**ប្រការ ៣** : ក.គ.អ.អ មានតួនាទីចុះកិច្ចព្រមព្រៀងជាមួយគណកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដើម្បីទទួលយកអនុកម្មវិធីទី ៤ របស់ផែនការអនុវត្តរយៈពេល ៣ឆ្នាំនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មកដំណើរការគ្រប់គ្រង និងអនុវត្តក្នុងក្របខ័ណ្ឌសម្របសម្រួលដោយលេខាធិការដ្ឋាននៃគណកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។៕

**ប្រការ ៤** : គ.គ.អ.អ មានភារកិច្ច៖

- រៀបចំ និងត្រួតពិនិត្យការអនុវត្តសកម្មភាពទាំងអស់នៃផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ដែលស្ថិតក្រោមក្របខ័ណ្ឌនៃអនុកម្មវិធី
- កៀរគរ និងតាមដានធាតុចូលនានា ដែលត្រូវការពីនាយកដ្ឋានផ្សេងៗរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានការពាក់ព័ន្ធទៅនឹងការអនុវត្តអនុកម្មវិធី
- តាមដានការអនុវត្តការងារទីប្រឹក្សាអភិវឌ្ឍសមត្ថភាពថ្នាក់ខេត្ត (ទីប្រឹក្សាហិរញ្ញវត្ថុខេត្ត)
- គ្រប់គ្រងកិច្ចសន្យារបស់ទីប្រឹក្សា និងកិច្ចសន្យាផ្តល់សេវាផ្សេងទៀត ពាក់ព័ន្ធទៅនឹងការអនុវត្តអនុកម្មវិធី
- គ្រប់គ្រងគណនីរបស់អនុកម្មវិធី
- ធ្វើរបាយការណ៍ជូន លេខាធិការដ្ឋាន គ.ជ.អ.ប និងគណៈកម្មការធិការដឹកនាំកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈស្តីពីការអនុវត្តអនុកម្មវិធី
- តំណាងឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងកិច្ចប្រជុំ និងព្រឹត្តិការណ៍នានាដែលរៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប ពាក់ព័ន្ធនឹងការអនុវត្ត អផ៣។

**ប្រការ ៥** : គ.គ.អ.អ មានលេខាធិការដ្ឋានស្ថិតនៅក្នុងទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៦** : អគ្គនាយកនៃអគ្គនាយកដ្ឋាន ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានការពាក់ព័ន្ធ និងសាមីជនដែលបានចែងក្នុងប្រការ ២ ត្រូវអនុវត្តតាមសេចក្តីប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

គាត ឈន់

ចម្លងជូន
-ក្រសួង ស្ថាប័នសមាជិក គ.ជ.អ.ប
-ដូចប្រការ ២ (ដើម្បីអនុវត្ត)
-ឯកសារ-កាលប្បវត្តិ